# មហាមោរជាតក



*ព្រះសាស្តាកាលស្តេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធឧក្កណ្ឋិតភិក្ខុ (ភិក្ខុអផ្សុកចង់សឹក) មួយរូប បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា* **សចេ ហិ ត្យាហំ ធនហេតុ គាហិតោ** *ដូច្នេះជាដើម ។*

*ព្រះសាស្តាត្រាស់សួរភិក្ខុនោះថា បានឮថា អ្នកអផ្សុកពិតមែនឬ ? កាលភិក្ខុនោះឆ្លើយថា ពិតមែនហើយព្រះអង្គ ។ ព្រះពុទ្ធត្រាស់ថា ម្នាលភិក្ខុ នន្ទិរាគៈនេះ ឈ្មោះថានឹងមិនញាំងអ្នកដែលមានសភាពបែបនេះឲ្យវិករវប្ម ខ្យល់ដែលបៀតបៀនភ្នំសិនេរុ នឹងមិនធ្វើស្លឹកឈើចាស់ក្នុងទីជិតឲ្យខ្ទាត់ខ្ទាយទៅឬ ក្នុងកាលមុន សូម្បីសត្វដែលបរិសុទ្ធ ហាមឃាត់ការប្រព្រឹត្តទៅរបស់កិលេសខាងក្នុង អស់ ៧០០ ឆ្នាំ ក៏នៅវិករវដែរ ដូច្នេះហើយ ព្រះអង្គនាំអតីតនិទានមកថា*

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ ក្នុងនគរពារាណសី ព្រះពោធិសត្វកាន់យកបដិសន្ធិក្នុងផ្ទៃមេក្ងោកមួយ ក្នុងបច្ចន្តប្រទេស ។ កាលគក៏ចាស់ហើយ មាតាញាំងពងឲ្យធ្លាក់ចុះលើភូមិភាគជាទីគោចរ ហើយចៀសចេញទៅ ។ ជាធម្មតាពងកាលមាតាមិនមានរោគ និងមិនមានអន្តរាយដទៃ ដោយទីយជាតិជាដើម ទើបមិនវិនាស ។ ព្រោះហេតុនោះ ពងនោះ ក៏មានពណ៌ដូចមាស ហាក់ដូចជាផ្កាកណិការក្រពុំ ក្នុងកាលពងចាស់ ក៏បែកតាមធម្មតារបស់ខ្លួន កើតជាកូនក្ងោកដែលមានសម្បុរមាស ចេញមក ។ កូនក្ងោកមាសនោះ មានភ្នែកទាំង ២ ប្រាកដដូចជាផ្លែទំពាំងបាយជូរ មានចំពុះពណ៌ដូចកែវប្រពាល មានករួបរឹតដោយឆ្នូតក្រហម ៣ រហូតដល់កណ្តាលខ្នង ។ កូនក្ងោកនោះ កាលចម្រើនវ័យធំហើយ មានខ្លួនធំប៉ុនរទេះដែលដឹកកណ្ឌៈ ជាសត្វមានរូបស្អាតយ៉ាងក្រៃលែង ។ ហ្វូងក្ងោកខៀវទាំងអស់ប្រជុំគ្នា ធ្វើក្ងោកមាសឲ្យជាព្រះរាជា នាំគ្នាឡោមព័ទ្ធជាបរិវារ ។

ថ្ងៃមួយ ស្តេចក្ងោកនោះ កាលផឹកទឹកត្រពាំង ឃើញរូបសម្បត្តិរបស់ខ្លួន ហើយគិតថា យើងមានរូបស្អាតដ៏លើសលុប ជាងក្ងោកទាំងពួង ប្រសិនបើយើងនៅក្នុងផ្លូវមនុស្សមួយអន្ទើដោយក្ងោកទាំងនេះ អន្តរាយនឹងកើតដល់យើង យើងត្រូវទៅព្រៃហិមពាន្ត ហើយនៅក្នុងទីដែលជាសុខតែម្នាក់ឯងប៉ុណ្ណោះ ។ ក្នុងពេលរាត្រី កាលក្ងោកទាំងឡាយដេកលក់អស់ហើយ ស្តេចក្ងោកនោះ មិនឲ្យអ្នកណាដឹងឡើយ ក៏ហើរចូលទៅកាន់ព្រៃហិមពាន្ត កន្លងជួរភ្នំ ៣ ទៅដល់ជួរភ្នំទី ៤ មានស្រះធម្មជាតិមួយដែលដេរដាសដោយផ្កាបទុម ក្នុងព្រៃមួយកន្លែង មានដើមជ្រៃធំឋិតនៅដោយអាស្រ័យភ្នំមួយ ក្នុងទីមិនឆ្ងាយពីស្រះនោះ ស្តេចក្ងោកពួនសម្ងំនៅនឹងមែកជ្រៃនោះ ។ នៅត្រង់កណ្តាលភ្នំនោះ មានគុហាដែលជាទីរីករាយមួយ ។ ស្តេចក្ងោកប្រាថ្នានឹងនៅក្នុងគុហានោះ ទើបហើរតម្រង់ទៅរកគុហា ហើយពួនសម្ងំនៅនឹងល្អាងភ្នំ ។ ទីនោះឯង អ្នកដែលនៅខាងក្រោម មិនអាចនឹងឡើងទៅបានឡើយ អ្នកដែលនៅ

ខាងលើក៏មិនអាចនឹងចុះមកដែរ ជាកន្លែងដែលរួចផុតភ័យពីសត្វធ្មា ទីឃជាតិ និងមនុស្ស ទាំងឡាយ ។ ស្តេចក្ងោកនោះគិតថា ទីនេះជាសុខដល់យើង ដូច្នេះ ថ្ងៃនោះឯង ក៏នៅក្នុង គុហានោះ ក្នុងថ្ងៃស្អែក ក្ងោកមាសហើរចេញពីគុហាភ្នំ មានមុខបែរទៅទិសខាងកើត ទំលើ កំពូលភ្នំ ឃើញមណ្ឌលព្រះសូរិយា ដែលកំពុងរះឡើង ក៏ធ្វើព្រះបរិត្តដើម្បីប្រយោជន៍ ដល់ រក្សាការពារខ្លួនក្នុងពេលថ្ងៃថា **ឧទេតយំ ចក្ខុមា ឯករាជា** ដូច្នេះជាដើម ទើបហើរចុះទៅ ស្វែងរកចំណី ត្រាច់រកចំណីហើយ ក្នុងពេលល្ងាច ក៏ហើរត្រឡប់មក មានមុខបែរទៅទិស ខាងលិច ទំលើកំពូលភ្នំ សម្លឹងមើលដួងព្រះសូរិយាដែលកំពុងអស្តង្គត ធ្វើព្រះបរិត្តដើម្បី ប្រយោជន៍ដល់ការរក្សាខ្លួនក្នុងពេលរាត្រីថា **អបេតយំ ចក្ខុមា ឯករាជា** (សេចក្តីពិស្តារ របស់ព្រះបរិត្តទាំងពីរនេះមានក្នុងមោរជាតក ឯកកនិបាត) ដូច្នេះជាដើម ស្តេចក្ងោកតែងតែ រស់នៅដោយឧបាយនោះ ។

ថ្ងៃមួយ នាយព្រានម្នាក់ កាលចូលទៅក្នុងព្រៃ បានឃើញក្ងោកមាសដែលកំពុងទំលើ កំពូលភ្នំ ហើយត្រឡប់មកលំនៅរបស់ខ្លួន ក្នុងពេលដែលគាត់ជិតនឹងមរណៈ បានពោល ដល់កូនថា ម្នាលកូន មានក្ងោកពណ៌មាសនៅនឹងជួរភ្នំទី ៤ ក្នុងព្រៃហិមពាន្ត បើព្រះរាជាសួរ អ្នកគប្បីទូលព្រះអង្គចុះ ។ ក្នុងថ្ងៃមួយ អគ្គមហេសីព្រះនាម **ខេមា** របស់ព្រះរាជាពារាណសី យល់ព្រះសុបិន ក្នុងបច្ចូសសម័យ ។ សុបិននោះមានសភាពបែបនេះ គឺ ឃើញក្ងោកពណ៌ មាសកំពុងសម្តែងធម៌ ព្រះនាងឲ្យសាធុការហើយ ស្តាប់ព្រះធម៌ ក្ងោកមាសសម្តែងធម៌ហើយ ក្រោកឡើង ហើរចេញទៅ ។ ព្រះនាងស្រែកថា ស្តេចក្ងោកហើរទៅហើយ ចូរចាប់ស្តេចក្ងោក ដូច្នេះហើយ ក៏ភ្ញាក់ឡើង កាលភ្ញាក់ហើយ ទើបដឹងថាជាសុបិន ព្រះនាងគិតថា បើយើងប្រាប់ ព្រះរាជាថាជាសុបិន ព្រះរាជានឹងមិនអើពើ យើងត្រូវទូលព្រះរាជាថា ជាសេចក្តីប្រាថ្នាដ៏ ចម្លែក ដូច្នេះហើយ ព្រះនាងធ្វើធ្វើដូចជាមានសេចក្តីប្រាថ្នាដ៏ចម្លែក ។ លំដាប់នោះ ព្រះរាជា

ចូលទៅជិតព្រះនាង សួរថា ម្នាលនាងដ៏ចម្រើន នាងមិនជាសុខ ដូចម្តេច ? ព្រះនាងខេមាទូលថា ចំណង់ចម្លែកកើតដល់ខ្ញុំម្ចាស់ ។ ព្រះរាជាសួរថា ម្នាលនាង នាងប្រាថ្នាអ្វី ? ព្រះនាងទូលថា បពិត្រព្រះទេវៈ ខ្ញុំម្ចាស់ចង់ស្តាប់ធម៌របស់ក្ងោកមាស ។ ព្រះរាជាត្រាស់ថា ម្នាលនាង តើយើងនឹងបានក្ងោកដែលរូបបែបនោះអំពីណា ។ ព្រះនាងទូលថា បពិត្រព្រះសម្មតិទេព បើខ្ញុំម្ចាស់មិនបានក្ងោកមាសនោះទេ ជីវិតរបស់ខ្ញុំម្ចាស់នឹងមិនមាន ។ ព្រះរាជាត្រាស់ថា ម្នាលនាង នាងកុំគិតអី បើក្ងោកមាសនោះមាន នាងនឹងបានក្ងោកនោះ ដូច្នេះហើយ ព្រះរាជាលួងលោមព្រះនាងឲ្យបានធូរស្បើយ រួចក៏យាងទៅ ប្រថាប់លើរាជាសនៈ សួរពួកអាមាត្យថា ម្នាលអ្នកដ៏ចម្រើនទាំងឡាយ ព្រះទេវីប្រាថ្នានឹងស្តាប់ធម៌របស់ក្ងោកមាស ឈ្មោះថាក្ងោកទាំងឡាយនឹងមានពណ៌មាសឬ ? ពួកអាមាត្យទូលថា បពិត្រព្រះសម្មតិទេព ព្រាហ្មណ៍ទាំងឡាយ រមែងដឹង ។

ព្រះរាជាត្រាស់ឲ្យហៅពួកព្រាហ្មណ៍មកសួរ ។ ព្រាហ្មណ៍ទាំងឡាយទូលថា បពិត្រមហារាជ រឿងនេះមានក្នុងលក្ខណមន្តរបស់ខ្ញុំព្រះអង្គថា មនុស្សសម្បុរមាស សត្វតិរច្ឆានពណ៌មាសទាំងឡាយគឺ ត្រីមាស អណ្តើកមាស ក្តាមមាស មាននៅក្នុងទឹក ម្រឹគមាស ហង្សមាស ក្ងោកមាស សត្វទទាមាស មាននៅលើគោក ។ ព្រះរាជាត្រាស់ហៅកូនព្រានដែលនៅក្នុងដែនរបស់ខ្លួនហើយសួរថា ក្ងោកមាស តើអ្នកទាំងឡាយធ្លាប់ឃើញទេ ? លុទ្ទបុត្តដ៏សេសទូលថា មិនធ្លាប់ឃើញទេ ។ ចំណែកកូនព្រាននោះទូលថា សូម្បីខ្ញុំព្រះអង្គក៏មិនធ្លាប់ឃើញដែរ តែបិតារបស់ខ្ញុំព្រះអង្គគាត់ពោលថា មានក្ងោកមាស នៅក្នុងទីឯណោះ ។ លំដាប់នោះព្រះរាជាត្រាស់នឹងគេថា នែសម្លាញ់ អ្នកចូរឲ្យជីវិតដល់ព្រះទេវីរបស់យើង អ្នកចូរទៅចាប់ក្ងោកមាសនោះ ហើយនាំមក ដូច្នេះទើបទ្រង់ប្រទានទ្រព្យដ៏ច្រើន ហើយបញ្ជូនកូនព្រាននោះទៅ ។ នាយព្រាននោះឲ្យទ្រព្យដល់កូននិងប្រពន្ធហើយ ក៏ទៅកាន់ព្រៃហិមពាន្ត គាត់

បានឃើញព្រះមហាសត្វ ទើបរៀបចំដាក់អន្ទាក់ដោយគិតថា ថ្ងៃនេះ យើងនឹងចាប់ក្ងោក នោះឲ្យបាន យើងនឹងចាប់ក្ងោកនោះឲ្យបាន ដូច្នេះហើយ កាលចាប់មិនបាន គាត់ក៏ស្លាប់ទៅ ចំណែកព្រះទេវីកាលមិនបានតាមសេចក្តីប្រាថ្នា ព្រះនាងក៏បានស្លាប់ទៅដែរ ។ ព្រះរាជាក្រោធថា ភរិយាជាទីស្រឡាញ់របស់យើងស្លាប់ព្រោះអាស្រ័យក្ងោកនោះ ដូច្នេះ ទ្រង់ចងសេចក្តីក្រោធ បញ្ជាឲ្យគេសរសេរលើក្រាំងមាសថា ក្នុងព្រៃហិមពាន្ត មានក្ងោកមាស រស់នៅនឹងជួរភ្នំទី ៤ អ្នកដែលបានបរិភោគសាច់ក្ងោកនោះ នឹងមិនចាស់ មិនស្លាប់ យ៉ាងនេះហើយ ដាក់ក្នុងហិបដែលដាក់របស់សំខាន់ (ចំណេរកាលតទៅ) ទ្រង់ក៏ធ្វើមរណកាល ។

លំដាប់នោះ ព្រះរាជាដទៃក៏បានសោយរាជសម្បត្តិបន្ត ។ ព្រះរាជានោះ ឃើញអក្សរក្នុងក្រាំងមាសហើយ គិតថា យើងនឹងមិនចាស់ មិនស្លាប់ ដូច្នេះបញ្ជូនកូនព្រានម្នាក់ ទៅដើម្បីចាប់ក្ងោកនោះ ។ សូម្បីកូនព្រានក៏បានស្លាប់ក្នុងទីនោះទៀត ។ ដោយទំនងយ៉ាងនេះឯង កន្លងទៅអស់ ៦ រជ្ជកាល កូនព្រាន ៦ នាក់ បានស្លាប់ក្នុងព្រៃហិមពាន្ត ។ ចំណែកកូនព្រានទី ៧ ដែលព្រះរាជាជំនាន់ទី ៧ បញ្ជូននោះ គិតថា ថ្ងៃនេះនឹងចាប់ក្ងោកមាសឲ្យបាន ដូច្នេះហើយ កាលមិនអាចដើម្បីចាប់អស់ ៧ ឆ្នាំ ទើបគិតថា ហេតុអ្វី បានជាអន្ទាក់មិនជាប់ជើងក្ងោកនេះ ។ លំដាប់នោះ កាលគាត់ឃ្លាំមើលក្ងោកនោះ ក៏បានឃើញក្ងោកធ្វើព្រះបរិត្តក្នុងពេលព្រឹក និងពេលល្ងាច កូនព្រានគិតថា ក្ងោកដទៃក្នុងទីនេះមិនមាន ក្ងោកនេះគង់ជាសត្វប្រព្រឹត្តព្រហ្មចរិយៈ ដោយអានុភាពនៃការប្រព្រឹត្តព្រហ្មចរិយៈ និងអានុភាពនៃព្រះបរិត្តបានជាជើងរបស់ក្ងោកមិនជាប់អន្ទាក់ ។ កូនព្រានកាន់យកន័យនេះហើយ ក៏ទៅកាន់បច្ចន្តជនបទ ចាប់ក្ងោកញីមួយ បង្ហាត់ឲ្យរងាវដោយការផ្ទាត់ម្រាមដៃ និងឲ្យរាំដោយការទះដៃ កាលឲ្យក្ងោកញីរៀនយ៉ាងនេះហើយ ចាប់យកទៅ រួចដាក់អន្ទាក់ មុនពេលដែលព្រះពោធិសត្វធ្វើព្រះបរិត្ត គាត់ផ្ទាត់ម្រាមដៃ ញុំាងឲ្យក្ងោកញីរងាវ ។ ស្តេចក្ងោកមាសស្តាប់

សំឡេងក្ងោកញីនោះហើយ កិលេសដែលដេកត្រាំខាងក្នុង អស់កាល ៧ ០០ ឆ្នាំរបស់ព្រះពោធិសត្វក៏ងើបឡើង ហាក់ដូចជា អាសិរពិសបើកពពារ ដែលត្រូវប្រហារដោយដំបង ។ ស្តេចក្ងោកនោះរឹករវដោយកិលេស មិនអាចនឹងធ្វើព្រះបរិត្ត ស្ទុះហើរទៅកាន់សម្នាក់ក្ងោកញីដោយរហ័ស ដាក់ជើងលើអន្ទាក់ ចុះអំពីអាកាស ។ អន្ទាក់មិនប្រព្រឹត្តទៅអស់ ៧ ឆ្នាំ ក្នុងខណៈនោះ ក៏ប្រព្រឹត្តទៅ ជាប់ជើងស្តេចក្ងោក ។

លំដាប់នោះ លុទ្ទបុត្តឃើញក្ងោកមាសជាប់អន្ទាក់ ព្យួរសំយុងចុះ ហើយគិតថា លុទ្ទ-បុត្ត ៦ នាក់ មិនអាចចាប់ស្តេចក្ងោកនេះបាន សូម្បីយើងមិនអាចចាប់ អស់ ៧ ឆ្នាំ តែថ្ងៃនេះស្តេចក្ងោករឹករវដោយកិលេស ព្រោះអាស្រ័យក្ងោកញីនេះ មិនអាចនឹងធ្វើព្រះបរិត្ត ចូលមកជាប់អន្ទាក់ មានក្បាលសំយុងចុះ សត្វដែលមានសីលយ៉ាងនេះ ត្រូវយើងធ្វើឲ្យលំបាក ការនាំសត្វបែបនេះទៅដើម្បីជាបណ្ណាការដល់ព្រះរាជា មិនសមគួរឡើយ ប្រយោជន៍អ្វីដោយសក្ការៈដែលព្រះរាជាប្រទាននោះ យើងលះបង់សក្ការៈនោះ ។ គាត់គិតទៀតថា ស្តេចក្ងោកនេះមានកម្លាំងដូចដំរីសារ កាលយើងចូលទៅ គង់តែនឹងគិតថា អ្នកនេះមកសម្លាប់ខ្លួនព្រោះខ្លាចសេចក្តីស្លាប់ កាលនឹងរើបម្រះ គប្បីដាច់ជើង និងស្លាប យើងមិនទាន់ចូលទៅទេ ត្រូវពួនកន្ទែងមួយ នឹងកាត់អន្ទាក់ដោយកូនសរ បន្ទាប់មក យើងនឹងចូលទៅតាមសេចក្តីពេញចិត្ត ។ កូនព្រាននោះ បិតនៅកន្ទែងបិទបាំងមួយ លើកធ្នូឡើង ត្របែងយឹតកូនសរ ។ ចំណែកស្តេចក្ងោក គិតថា ព្រាននេះធ្វើឲ្យយើងរឹករវដោយកិលេស ដឹងថាយើងជាប់អន្ទាក់នឹងមកដោយឥតសង្ស័យ ចុះគេនោះនៅឯណា ដូច្នេះទើបតាំងចិត្តហើយ សម្លឹងរកមើលឃើញព្រានឈរលើកធ្នូ ក៏សម្គាល់ថា ព្រាននេះសម្លាប់យើង រួចកាន់យកទៅ ដូច្នេះ ស្តេចក្ងោកខ្លាចសេចក្តីស្លាប់ កាលនឹងសូមជីវិត ទើបពោលគាថាទី ១ ថា

**សចេ ហិ ត្យាហំ ធនហេតុ គាហិតោ, មា មំ វធី ជីវគាហំ គហេត្វា;**

**រញ្ញោ ច មំ សម្ម ឧបន្តិកំ នេហិ, មញ្ញេ ធនំ លច្ឆសិនប្បរូបំ។**

*ម្នាលសម្លាញ់ ប្រសិនបើអ្នកចាប់ខ្ញុំ ព្រោះហេតុនៃទ្រព្យ អ្នកកុំសម្លាប់ខ្ញុំឡើយ សូមចាប់ខ្ញុំទាំងរស់ ហើយនាំខ្ញុំទៅកាន់សំណាក់ព្រះរាជាចុះ អ្នកទំនងជានឹងបាននូវទ្រព្យដ៏ច្រើន ។*

*លុទ្ទបុត្តស្តាប់ពាក្យនោះហើយ គិតថា ស្តេចក្ងោកសម្គាល់ថា ព្រាននេះយឹតកូនសរ ព្រោះប្រាថ្នានឹងបាញ់ខ្លួន យើងនឹងលួងលោមស្តេចក្ងោក ។ កូនព្រានកាលនឹងលួងលោម ទើបពោលគាថាទី ២ ថា*

**ន មេ អយំ តុយ្ហ វធាយ អជ្ជ, សមាហិតោ ចាបធុរេ ខុរប្បោ;**
**បាសញ្ច ត្យាហំ អធិបាតយិស្សំ, យថាសុខំ គច្ឆតុ មោររាជ។**

*ធ្នូដ៏ប្រសើរនិងព្រួញនេះ ខ្ញុំមិនមែនយឹត ប្រុងប្រៀបដើម្បីនឹងបាញ់អ្នកក្នុងថ្ងៃនេះទេ ខ្ញុំនឹងបាញ់ផ្តាច់អន្ទាក់របស់អ្នកទេតើ ( ដោយគិតថា) ស្តេចក្ងោកចូរទៅតាមសប្បាយចុះ ។*

*លំដាប់នោះ មោររាជពោល ២ គាថា ថា*

**យំ សត្ត វស្សានិ មមានុពន្ធិ, រត្តិន្ទិវំ ខុប្បិបាសំ សហន្តោ;**
**អថ កិស្ស មំ បាសវសូបនីតំ, បមុត្តវេ ឥច្ឆសិ ពន្ធនស្មា។**

*អ្នកខំអត់ទ្រាំនូវសេចក្តីស្រេកឃ្លាន ទាំងយប់ទាំងថ្ងៃ ដើរជាប់តាមខ្ញុំអស់ប្រាំពីរឆ្នាំហើយ កាលបើយ៉ាងនេះ ព្រោះហេតុអ្វី ក៏អ្នកចង់ដោះខ្ញុំ ដែលកំពុងជាប់អន្ទាក់ ឲ្យរួចអំពីអន្ទាក់វិញ ។*

**បាណាតិបាតា វិរតោ នុសជ្ជ, អភយំ នុ តេ សព្ពភូតេសុ ទិន្នំ;**
**យំ មំ តុវំ បាសវសូបនីតំ, បមុត្តវេ ឥច្ឆសិ ពន្ធនស្មា។**

អ្នកទើបនឹងវៀរចាកបាណាតិបាត ក្នុងថ្ងៃនេះឬ ឬក៏អ្នកឲ្យអភ័យដល់សត្វទាំងពួង បាន ជាអ្នកចង់ដោះខ្ញុំ ដែលកំពុងជាប់អន្ទាក់ឲ្យរួចចាកអន្ទាក់វិញ ។

អធិប្បាយថា អ្នកជាប់តាមខ្ញុំអស់កាលប្រមាណប៉ុណ្ណេះ ព្រោះហេតុណា ព្រោះហេតុ នោះ ខ្ញុំសូមសួរអ្នក កាលបើយ៉ាងនោះ ព្រោះហេតុអ្វី បានជាអ្នកចង់ដោះលែងខ្ញុំ អំពីចំណង ដែលចូលក្នុងអំណាចនៃអន្ទាក់ ។

តទៅនេះ អ្នកសិក្សាគប្បីជ្រាបសេចក្តីសម្ព័ន្ធនៃគាថាឆ្លងឆ្លើយ ដោយបាឡីនេះថា

**កូនព្រានពោលថា**

បាណាតិបាតា វិរតស្ស ព្រូហិ, អភយញ្ច យោ សព្វភូតេសុ ទេតិ;
បុច្ឆាមិ តំ មោររាជេតមត្ថំ, ឥតោ ចុតោ កិំ លភតេ សុខំ សោ។

ម្នាលស្តេចក្ងោក អ្នកចូរប្រាប់អំពីបុគ្គលដែលវៀរចាកបាណាតិបាតផង អ្នកដែលឲ្យនូវ អភ័យដល់សត្វទាំងពួងផង ខ្ញុំសូមសួរអ្នកត្រង់សេចក្តីនុ៎ះ បុគ្គលនោះច្យុតអំពីលោកនេះទៅ នឹងបាននូវសេចក្តីសុខដូចម្តេចខ្លះ ។

**ស្តេចក្ងោកពោលថា**

បាណាតិបាតា វិរតស្ស ព្រូមិ, អភយញ្ច យោ សព្វភូតេសុ ទេតិ;
ទិដ្ឋេវ ធម្មេ លភតេ បសំសំ, សគ្គញ្ច សោ យាតិ សរីរភេទា។

ខ្ញុំនឹងប្រាប់អំពីបុគ្គល ដែលវៀរចាកបាណាតិបាតផង អ្នកដែលឲ្យនូវអភ័យដល់សត្វ ទាំងពួង បុគ្គលនោះរមែងបាននូវសេចក្តីសរសើរ ក្នុងបច្ចុប្បន្នផង លុះបែកធ្លាយសរីរៈទៅ នឹង បានទៅកើតនៅឋានសួគ៌ផង ។

កូនព្រានពោលថា

ន សន្តិ ទេវា ឥតិ អាហុ ឯកេ, ឥធេវ ជីវោ វិភវំ ឧបេតិ;
តថា ផលំ សុកតទុក្កដានំ, ទត្តុបញ្ញត្តញ្ច វទន្តិ ទានំ;
តេសំ វចោ អរហតំ សទ្ទហានោ, តស្មា អហំ សកុណេ ហនយាមិ។

*សមណព្រាហ្មណ៍ពួកខ្លះបានពោលថា ទេវតាទាំងឡាយមិនមានទេ ជីវៈក្នុងលោកនេះ រមែងដល់នូវសេចក្តីដាច់សូន្យ ផលនៃអំពើ ដែលសត្វធ្វើល្អ ធ្វើអាក្រក់ រមែងដល់នូវ សេចក្តីដាច់សូន្យដូចគ្នា ទាំងពោលថា ទានជាគុណជាតតឹមនុស្សល្ងង់បញ្ញត្តហើយ ខ្ញុំជឿពាក្យរបស់សមណព្រាហ្មណ៍ ជាព្រះអរហន្តទាំងនោះ ហេតុនោះបានជាខ្ញុំសម្លាប់សត្វស្លាបទាំងឡាយ ។*

*ពាក្យថា* ***ខ្ញុំជឿពាក្យរបស់សមណព្រាហ្មណ៍ ជាព្រះអរហន្តទាំងនោះ*** *សេចក្តីថា បានឮថា ពួកអចេលក៍ (អ្នកបួសស្រាត) ដែលជាឧច្ឆេទវាទី (អ្នកមានការពោលថាដាច់សូន្យ) ជាកុលូបកៈ (អ្នកចូលទៅកាន់ត្រកូល) របស់កូនព្រាននោះ ។ ពួកអចេលក៍នោះញុំាងសត្វសូម្បីដែលដល់ព្រមដោយឧបនិស្ស័យនៃបច្ចេកពោធិញាណ ឲ្យកាន់យកឧច្ឆេទវាទ ។ ព្រោះការសេពគប់ជាមួយអចេលក៍ទាំងនោះ កូនព្រានកាន់យកថា ផលរបស់កុសលកម្ម អកុសលកម្ម មិនមាន ដូច្នេះទើបសម្លាប់បក្សីទាំងឡាយ ។ ឈ្មោះថា ការសេពគប់នឹងអសប្បុរស រមែងមានទោសច្រើនយ៉ាងនេះ ។ កូនព្រាននោះសម្គាល់ថា អចេលក៍នោះ ថាជាព្រះអរហន្ត ទើបពោលយ៉ាងនេះថា អរហន្តោ ។*

*ព្រះមហាសត្វស្តាប់ពាក្យនោះហើយ គិតថា យើងនឹងសម្តែងភាវៈមាននៃបរលោកដល់ព្រាននោះ ទាំងដែលមានក្បាលសំយុងចុះក្រោម ព្យួរនៅនឹងដងអន្ទាក់ ក៏ពោលគាថានេះថា*

**ចន្ទោ ច សុរិយោ ច ឧភោ សុទស្សនា, គច្ឆន្តិ ឱភាសយមន្តលិក្ខេ,**
**ឥមស្ស លោកស្ស បរស្ស វា តេ, កថំ នុ តេ អាហុ មនុស្សលោកេ។**

*ព្រះចន្ទ្រនិងព្រះអាទិត្យទាំងពីរ ជារបស់ឃើញងាយ ភ្លឺ រុងរឿង ទៅឮដំអាកាស ព្រះ ចន្ទ្រនិងព្រះអាទិត្យទាំងនោះ (ជារបស់) លោកនេះ ឬជារបស់លោកដទៃ (ពួកជន) ក្នុងមនុស្សលោកហៅព្រះចន្ទ្រនិងព្រះអាទិត្យទាំងនោះថាជាអ្វី ។*

*ពាក្យថា (ពួកជន) ក្នុងមនុស្សលោកហៅព្រះចន្ទ្រ និងព្រះអាទិត្យទាំងនោះ ថាជាអ្វី សេចក្ដីថា ពួកមនុស្សហៅចន្ទិមទេវបុត្រ និងសូរិយទេវបុត្រដែលនៅក្នុងវិមាននោះថាជាអ្វី ពួកគេពោលថា មាន ឬ មិនមាន ឬក៏ហៅថា ជាទេវតា ឬជាមនុស្ស ។*

*លុទ្ទបុត្រពោលគាថាថា*

**ចន្ទោ ច សុរិយោ ច ឧភោ សុទស្សនា, គច្ឆន្តិ ឱភាសយមន្តលិក្ខេ,**
**បរស្ស លោកស្ស ន តេ ឥមស្ស, ទេវាតិ តេ អាហុ មនុស្សលោកេ។**

*ព្រះចន្ទ្រនិងព្រះអាទិត្យទាំងពីរ ជារបស់ឃើញងាយ ភ្លឺរុងរឿង ទៅឮដំអាកាស ព្រះ ចន្ទ្រនិងព្រះអាទិត្យទាំងនោះ (ជារបស់) លោកដទៃ មិនមែនរបស់លោកនេះទេ ពួកជនក្នុងមនុស្សលោក ហៅព្រះចន្ទ្រ និងព្រះអាទិត្យទាំងនោះថាជា ទេវតា ។*

*លំដាប់នោះ ព្រះមហាសត្វពោលនឹងកូនព្រានថា*

**ឯត្ថេវ តេ នីហតា ហីនវាទា, អហេតុកា យេ ន វទន្តិ កម្មំ;**
**តថា ផលំ សុកតទុក្កដានំ, ទត្តុបញ្ញត្តំ យេ ច វទន្តិ ទានំ។**

*សមណព្រាហ្មណ៍ណា មិនពោលអាងកម្ម មិនពោលអាងផលនៃកម្ម ដែលសត្វធ្វើល្អ ធ្វើអាក្រក់ មួយទៀត សមណព្រាហ្មណ៍ណា ពោលថា ទានជាគុណជាតដែលមនុស្សល្ងង់បញ្ញត្តហើយ សមណព្រាហ្មណ៍ទាំងនោះជាអ្នកហីនវាទ ជាអ្នកអហេតុកវាទ ត្រូវគេដេញដើងទាល់ក្នុងព្យាករណ៍នេះ មិនខាន ។*

*ពាក្យថា **សមណព្រាហ្មណ៍ទាំងនោះជាអ្នកហីនវាទ ជាអ្នកអហេតុកវាទ ត្រូវគេដេញដើង ទាល់ក្នុងព្យាករណ៍នេះ** សេចក្តីថា បើព្រះចន្ទ្រ និងព្រះអាទិត្យឋិតនៅក្នុងទេវលោក មិនមែនក្នុងមនុស្សលោក, បើចន្ទិមទេវបុត្រ និងសូរិយទេវបុត្រជាទេវតា មិនមែនជាមនុស្ស, ពួកអចេលក៍ដែលជាកុលូបកៈ របស់អ្នកនោះ ជាហីនវាទ ត្រូវគេដេញដើងទាល់ ក្នុងព្យាករណ៍នេះ មិនខាន ។ ពាក្យថា **ជាអហេតុកវាទ** សេចក្តីថា អ្នកមានវាទយ៉ាងនេះថា កម្មដែលជាហេតុនៃសេចក្តីបរិសុទ្ធ និងសេចក្តីសៅហ្មង រមែងមិនមាន ។*

*កាលព្រះមហាសត្វពោលយ៉ាងនេះហើយ កូនព្រាននោះ ក៏កំណត់ដឹង ហើយពោល ២ គាថាថា*

**អទ្ធា ហិ សច្ចំ វចនំ តវេតំ, កថញ្ហិ ទានំ អផលំ ករេយ្យ;**
**តថា ផលំ សុកតទុក្កដានំ, ទត្តុបញ្ញត្តញ្ច កថំ ករេយ្យ។**

*ពាក្យរបស់អ្នកនុ៎ះទៀងពិត ព្រោះទានជាគុណជាតឥតផលដូចម្តេចកើត ផលនៃអំពើដែលសត្វធ្វើល្អធ្វើអាក្រក់ក៏ដូចគ្នា ម្យ៉ាងទៀត (ទាន) ជាគុណជាតដែលមនុស្សល្ងង់បញ្ញត្តហើយ ដូចម្តេចកើត ។*

**កថំករោ កិន្តិករោ កិមាចរំ, កិំ សេវមានោ កេន តវោគុណេន;**
**អក្ខាហិ មេ មោរាជេតមត្ថំ, យថា អហំ នោ និរយំ បតេយ្យំ។**

*ខ្ញុំធ្វើអំពើដូចម្តេច ធ្វើដោយហេតុដូចម្តេច ប្រព្រឹត្តដូចម្តេច សេពនូវអ្វី ដោយគុណនៃតបៈដូចម្តេច មិនគប្បីធ្លាក់ទៅក្នុងនរក យ៉ាងណា ម្នាលស្តេចក្ងោក អ្នកសូមប្រាប់សេចក្តីនុ៎ះដល់ខ្ញុំ ដោយឧបាយ យ៉ាងនោះ ។*

*ព្រះមហាសត្វស្តាប់ពាក្យនោះហើយគិតថា បើយើងមិនឆ្លើយបញ្ហានេះទេ មនុស្សលោកនឹងប្រព្រឹត្តដូចជាសូន្យទទេ យើងនឹងសម្តែងភាពមាននៃសមណព្រាហ្មណ៍ ដែលប្រកបដោយធម៌ ដល់ព្រាននេះ ដូច្នេះទើបពោល ២ គាថាថា*

យេ កេចិ អត្ថិ សមណា បថព្យា, កាសាយវត្ថា អនគារិយា តេ,
ចាតោវ បិណ្ឌាយ ចរន្តិ កាលេ, វិកាលចរិយា វិរតា ហិ សន្តោ។

*ពួកសមណៈណាមួយនៅលើផែនដី ជាអ្នកស្លៀកសំពត់កាសាវៈ ប្រព្រឹត្តក្នុងភេទនៃបុគ្គលគ្មានផ្ទះ ត្រេចទៅបិណ្ឌបាតអំពីព្រឹក ក្នុងកាលគួរ វៀចាកកិរិយាត្រេចទៅក្នុងកាលខុស ជាអ្នកស្ងប់រម្ងាប់ ។*

តេ តត្ថ កាលេនុបសង្កមិត្វា, បុច្ឆាហិ យំ តេ មនសោ បិយំ សិយា;
តេ តេ បវក្ខន្តិ យថាបជានំ, ឥមស្ស លោកស្ស បរស្ស ចត្ថំ។

*អ្នកចូរទៅរកសមណៈទាំងនោះ តាមការគួរក្នុងទីនោះហើយ ចូរសាកសួរចុះប្រយោជន៍ណា ដែលជាទីពេញចិត្តរបស់អ្នក លោកនឹងប្រាប់នូវប្រយោជន៍ ជាប្រយោជន៍ក្នុងលោកនេះ និងក្នុងលោកខាងមុខ (ដល់អ្នក) តាមទំនងនៃការចេះដឹង (របស់លោក) ។*

*ពាក្យថា **អ្នកស្ងប់រម្ងាប់** ក្នុងគាថានោះ បានដល់ ព្រះបច្ចេកពុទ្ធអ្នកស្ងប់រម្ងាប់នូវបាបលោកជាបណ្ឌិត ។ ពាក្យថា **តាមទំនងនៃការចេះដឹង** សេចក្តីថា លោកនឹងប្រាប់តាមនិយាមនៃចំណេះដឹងរបស់ខ្លួនដល់អ្នក នឹងកាត់សេចក្តីសង្ស័យរបស់អ្នក ហើយសម្តែង ។ ពាក្យថា*

***ប្រយោជន៍ក្នុងលោកនេះ និងក្នុងលោកខាងមុខ*** *សេចក្ដីថា សមណព្រាហ្មណ៍នោះនឹងប្រាប់នូវប្រយោជន៍ក្នុងលោកនេះ និងក្នុងលោកខាងមុខដល់អ្នកថា កម្មនេះនាំឲ្យកើតក្នុងមនុស្សលោក កម្មនេះនាំឲ្យកើតក្នុងទេវលោក កម្មនេះនាំឲ្យកើតក្នុងអបាយភូមិមាននរកជាដើម ។*

*កាលមោររាជពោលយ៉ាងនេះហើយ បានញាំងលុទ្ទបុត្តឲ្យភ័យខ្លាចចំពោះនរក ។ ចំណែកលុទ្ទបុត្តនោះ ជាបច្ចេកពោធិសត្វ ដែលមានបារមីពេញបរិបូណ៌ហើយ មានញាណចាស់ក្លាហើយ ហាក់ដូចជា ផ្កាបទុមដែលបិតនៅ រង់ចាំសម្ផស្សរស្មីព្រះសូរិយា ។ លុទ្ទបុត្តនោះ កាលស្ដាប់ធម្មកថារបស់ព្រះពោធិសត្វ ឈរបិតដោយជើងនោះឯង ពិចារណាសង្ខារធម៌ ពិចារណាត្រៃលក្ខណ៍ ក៏បានត្រាស់ដឹងបច្ចេកពោធិញាណ ។ ការចាក់ធ្លុះចំពោះកិរិយាត្រាស់ដឹងរបស់កូនព្រាននោះ និងការរួចផុតពីអន្ទាក់របស់ព្រះមហាសត្វ មានក្នុងពេលតែមួយ ។ ព្រះបច្ចេកពុទ្ធទម្លាយកិលេសទាំងពួងហើយ តាំងនៅក្នុងទីបំផុតនៃភព កាលបន្លឺនូវឧទាន ទើបត្រាស់គាថាថា*

**តចំវ ជិណ្ណំ ឧរគោ បុរាណំ, បណ្ឌុបលាសំ ហរិតោ ទុមោវ;**
**ឯសប្បហីនោ មម លុទ្ទភាវោ, ជហាមហំ លុទ្ទកភាវមជ្ជ។**

***ភាពជាព្រានព្រៃនុ៎ះ អាត្មាអញបានលះបង់ហើយ អាត្មាអញបានលះបង់នូវភាពនៃខ្លួនជាព្រានព្រៃក្នុងថ្ងៃនេះ ដូចពស់សកនូវសំណកចាស់ជាន់មុន ឬក៏ដូចដើមឈើមានស្លឹកខៀវ (ជម្រុះចោល) នូវស្លឹកលឿង ។***

*គាថានេះ មានសេចក្ដីអធិប្បាយថា ពស់សកសំណកចាស់យ៉ាងណា និងដើមឈើមានស្លឹកខៀវ ជម្រុះចោលស្លឹកលឿងដែលបិតនៅក្នុងទីខ្លះ យ៉ាងណា ថ្ងៃនេះ សូម្បីអាត្មា*

អញក៏លះចោលនូវភាពជាព្រាន និងភាពអាក្រក់ ហើយតាំងនៅ ឥឡូវនេះ ភាពជាព្រាន នោះ គឺអាត្មាអញបានលះបង់ហើយ ។

ព្រះបច្ចេកពុទ្ធបន្ទឹឧទាននេះហើយ គិតថា អាត្មាអញរួចផុតពីចំណង គឺកិលេស ទាំងពួងហើយ តែមានបក្សីជាច្រើន ដែលអាត្មាអញបានចងទុកនិវេសន៍ អាត្មាអញនឹងឲ្យ បក្សីទាំងនោះរួចផុត ដូចម្តេច ដូច្នេះហើយ ក៏សួរព្រះមហាសត្វថា ម្នាលមោររាជ មានបក្សីជា ច្រើនជាប់ចំណងក្នុងនិវេសន៍របស់អាត្មា អាត្មានឹងឲ្យបក្សីទាំងនោះរួច ដូចម្តេច ? ពិតមែន ហើយ **ឧបាយបរិគ្គហញាណ** (បញ្ញាពិចារណារកឧបាយ) របស់សព្វញ្ញុពោធិសត្វទាំងឡាយ នោះឯង រមែងធំជាងព្រះបច្ចេកពុទ្ធ ព្រោះហេតុនោះ មោររាជទើបពោលនឹងព្រះបច្ចេកពុទ្ធ នោះថា បច្ចេកពោធិញាណណា ដែលព្រះអង្គកាត់កិលេស ហើយចាក់ធ្លុះដោយអរិយមគ្គ ព្រះអង្គចូរប្រារព្ធបច្ចេកពោធិញាណនោះ និងចូរធ្វើសច្ចកិរិយាចុះ ឈ្មោះថា សត្វដែលជាប់ ចំណងក្នុងសកលជម្ពូទ្វីប នឹងមិនមាន ។ ព្រះបច្ចេកពុទ្ធនោះ តាំងនៅក្នុងទ្វារន័យដែលព្រះ ពោធិសត្វឲ្យហើយ កាលនឹងធ្វើសច្ចកិរិយា ទើបត្រាស់ព្រះគាថាថា

**យេ ចាបិ មេ សកុណា អត្ថិ ពទ្ធា, សតានិនេកានិ និវេសនស្មឹ;**
**តេសប្បហំ ជីវិតមជ្ជ ទម្មិ, មោក្ខញ្ច តេ បត្តា សកំ និកេតំ។**

***ពួកបក្សីណាច្រើនរយ ដែលអាត្មាអញបានចងទុកក្បែរលំនៅ (របស់ខ្លួន) អាត្មាអញ នឹងឲ្យនូវជីវិតដល់សត្វទាំងឡាយនោះ ក្នុងថ្ងៃនេះ អាត្មាអញបានរួចចាកកិលេសហើយ សត្វ ទាំងនោះ ចូរទៅកាន់លំនៅរបស់ខ្លួនចុះ ។***

ពាក្យថា **អាត្មាអញបានរួចចាកកិលេសហើយ** សេចក្តីថា អាត្មាបានដល់ការរួចផុត គឺ បានបន្ទុះបច្ចេកពោធិញាណហើយ អាត្មានឹងសង្គ្រោះសត្វទាំងឡាយនោះដោយជីវិតទាន

*(ការឲ្យជីវិត) ដោយពាក្យសច្ចៈនេះ ។ ពាក្យថា* ***សត្វទាំងនោះ ចូរទៅកាន់លំនៅរបស់ខ្លួនចុះ*** *សេចក្តីថា ព្រះបច្ចេកពុទ្ធត្រាស់ថា សត្វទាំងឡាយនោះសូម្បីទាំងអស់ ចូរទៅកាន់លំនៅរបស់ខ្លួនៗចុះ ។*

*លំដាប់នោះ សត្វទាំងអស់ក៏រួចផុតពីចំណង តំណាលគ្នានឹងពេលដែលព្រះបច្ចេកពុទ្ធធ្វើសច្ចកិរិយានោះឯង ។ សត្វទាំងនោះស្រែកដោយសំឡេងរីករាយ ទៅកាន់លំនៅរបស់ខ្លួន ។ ក្នុងខណៈនោះ បណ្តាសត្វទាំងឡាយក្នុងផ្ទះនោះៗ មានឆ្មាជាដើម ឈ្មោះថាសត្វដែលជាប់ចំណងក្នុងសកលជម្ពូទ្វីប រមែងមិនមាន ។ ព្រះបច្ចេកពុទ្ធយកដៃស្ទាបសីសៈ ។ ភេទជាគ្រហស្ថ ក៏អន្តរធានទៅ ភេទជាបព្វជិតប្រាកដឡើងជំនួស ។ ព្រះបច្ចេកពុទ្ធនោះ ជាអ្នកដល់ព្រមដោយអាកប្បកិរិយា ហាក់ដូចជា ព្រះថេរៈដែលមានវស្សា ៦០ ជាអ្នកទ្រទ្រង់អដ្ឋបរិក្ខារ[១] ហើយពោលថា អ្នកចូរជាទីពឹងរបស់អាត្មា ដូច្នេះហើយ ផ្គងអញ្ជលី[២] ធ្វើប្រទក្សិណស្តេចក្ងោក ហើយហោះឡើងលើអាកាស ទៅកាន់ញកភ្នំនន្ទមូលក៍ ។ ចំណែកមោររាជ ហើរចេញពីចុងអន្ទាក់ ត្រាច់ស្វែងរកចំណី រួចក៏ទៅលំនៅរបស់ខ្លួនវិញ ។*

*ឥឡូវនេះ ព្រះសាស្តាកាលប្រកាសភាពជាអ្នករួចផុតពីទុក្ខ របស់នាយព្រាន ដែលប្រព្រឹត្តដាក់អន្ទាក់ដោយដៃអស់ ៧ ឆ្នាំ ព្រោះអាស្រ័យស្តេចក្ងោក ទើបព្រះអង្គត្រាស់ឱសានគាថាថា*

**លុទ្ទោ ចរី ទាសហាត្តោ អរញ្ញេ, ពាធេតុ មោរាធិបតឹ យសស្សឹ;**
**ពន្ធិត្វា មោរាធិបតឹ យសស្សឹ, ទុក្ខា ស បមុច្ចិ យថាហំ បមុត្តោ។**

---

*១. អដ្ឋបរិក្ខារ (បរិក្ខារ ៨) បានដល់* **សង្ឃាដិ** *សង្ឃាដី ១* **ឧត្តរាសង្គោ** *ចីវរ ១* **អន្តរវាសកោ** *ស្បង់ ១* **បត្តោ** *បាត្រ ១* **វាសិ** *កាំបិតកោរ ១* **សូចិ** *ម្ជុល ១* **ពន្ធនំ** *វត្តពន្ធ ១* **បរិស្សាវនំ** *សំពត់តម្រងទឹក ១ (បបញ្ចសូទនី អដ្ឋកថា អង្គុលិមាលសូត្រ) ។ ២. អញ្ជលិ ( ន. ) [អ័ញ-ជៈ--] or អញ្ជលី ( បា., សំ. ) (បញ្ជលិ ឬប្រើជា អញ្ជលីក៏មាន; អញ្ជលិ) ក្រពុំម្រាមដៃ (ទាំង១០), ការផ្គុំម្រាមដៃទាំង១០គោរព ។*

*ព្រានព្រៃមានអន្ទាក់ក្នុងដៃ ត្រេចទៅក្នុងព្រៃដើម្បីទាក់នូវស្តេចក្ងោក ដែលមានយស លុះទាក់នូវស្តេចក្ងោកដែលមានយសបានហើយ ក៏បានរួចចាកសេចក្តីទុក្ខ ដូចតថាគតដែលបានរួច ( ចាកទុក្ខដោយសយម្ភូញាណ) ដូច្នោះដែរ ។*

*ពាក្យថា **លុះទាក់នូវស្តេចក្ងោកដែលមានយសបានហើយ** សេចក្តីថា លុះនាយព្រានទាក់ស្តេចក្ងោកបានហើយ ឈរស្តាប់ធម្មកថា ជាអ្នកបាននូវសេចក្តីសង្វេគ ។ ពាក្យថា **ដូចតថាគតដែលបានរួចដូច្នោះដែរ** សេចក្តីថា តថាគតជាអ្នករួចផុតដោយសយម្ភុញាណយ៉ាងណា សូម្បីនាយព្រាននោះក៏បានរួចផុត យ៉ាងនោះដែរ ។*

*ព្រះសាស្តានាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចធម៌ និងប្រជុំជាតក ក្នុងទីបំផុតនៃសច្ចធម៌ ឧក្កណ្ឋិតភិក្ខុបានសម្រេចព្រះអរហត្ត ។*

**តទា មោររាជា អហមេវ អហោសឹ** *មោររាជក្នុងកាលនោះ គឺតថាគតនេះឯង ។*

*ចប់ មហាមោរជាតក ៕*

*(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក បកិណ្ណកនិបាត បិដលេក ៦០ ទំព័រ ៣១)*

*ថ្ងៃសៅរ៍ ១១ កើត ខែមបមាសាឍ ឆ្នាំច សំរិទ្ធិស័ក ព.ស. ២៥៦២ ច.ស. ១៣៨០ ម.ស. ១៩៤០*

*ថ្ងៃទី ២៣ ខែ មិថុនា គ.ស.២០១៨*

*ដោយស.ដ.វ.ថ.*